## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦

## ស្តីពីលិខិតសរសើររបស់រដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន

នៅថ្ងៃទី១៣ ខែកក្កដា ក្រសួងការបរទេសជប៉ុន បានចេញសេចក្តីប្រកាសព័ត៌មានស្តីអំពីលិខិតសរសើររដ្ឋមន្ត្រីការបរទេសជូនចំពោះបុគ្គល ឬក្រុមដែលមានស្នាដៃឆ្នើមលើវិស័យអន្តរជាតិក្នុងឆ្នាំនេះ ដើម្បីជាការទទួលស្គាល់នូវការរួមចំណែករបស់ពួកគេលើការជម្រុញនូវចំណងមិត្តភាពរវាងជប៉ុន និង បណ្តាប្រទេសនានា។

អ្នកដែលទទួលបានលិខិតសរសើរចំពោះសកម្មភាពនានារបស់លោក លោកស្រីនៅក្នុងប្រទេសកម្ពុជាមានដូចខាងក្រោម៖

- **លោក គូជិ តេហ្សឺកា** ជាទីប្រឹក្សា នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នឹងទទួលលិខិតសរសើរចំពោះការរួមចំណែករបស់លោកក្នុងការជម្រុញការយល់ដឹងពីគ្នាទៅវិញទៅមករវាងជប៉ុន និងកម្ពុជា

- **លោកស្រី ឡុច លក្ខ័ស្មី** ប្រធានដេប៉ាតឺម៉ង់ភាសាជប៉ុន នៃវិទ្យាស្ថានភាសាបរទេសសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នឹងទទួលលិខិតសរសើរដល់ការរួមចំណែករបស់លោកស្រីក្នុងការលើកស្ទួយការសិក្សាភាសាជប៉ុននៅប្រទេសកម្ពុជា

ពិធីប្រគល់លិខិតសរសើរនឹងរៀបចំនាពេលខាងមុខ។

---

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 216 162; Email: info.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*